D03140
TSL ~~Box~~ 5006

- ឈ្មោះ : ទៀប . ណាន
- នាទី យុទ្ធជន អង្គភាពវ.៥៣១៧

កងពល ៣១០

ចូល បក្សពលករ នៅថ្ងៃទី១៥.១.៧៦

អំពីខ្សែបក្សពួក របស់ឈ្មោះ
ឌេប.ទឹង ហៅ ណាត
តាំងពីដើម រហូតមកទល់បច្ចុប្បន្ន

១.- ណន នាទី យ.ធវរធំ ១២ កងពល៣១០ បច្ចុប្បន្ន ចាប់ហើយ ៧

២.- ស៊ែស នាទី យ.ធវរតូច១២១ វរធំ១២ កងពល៣១០ ចាប់ហើយ ៧

៣.- ណូ នាទី អនុន.ប ១២១ វរធំ១២ កងពល៣១០ ចាប់ហើយ ៧

៤.- ធាន នាទី ភស្តុភា ១២១ វរធំ១២ កងពល៣១០ ចាប់ហើយ ៧

៥.- ទៀន នាទី ន.បកងធំ - វរធំ១២ កងពល៣១០ ចាប់ហើយ ៧

៦.- ងីម នាទី ន.បកងធំ - វរធំ១២ កងពល៣១០ ចាប់ហើយ ៧

៧.- សាង នាទីអនុន.បកងធំ - វរធំ១២ កងពល៣១០ នៅវរតូច៣១៧ ៧

៨.- ផាន នាទីអនុយ.ធកងធំ - វរធំ១២ កងពល៣១០ នៅវរតូច៣១៧ ៧

៩.- តាក់ នាទីអនុន.បកងធំ - វរធំ១២ កងពល៣១០ ចាប់ហើយ ៧

១០.- ឈឿន នាទី យ.ធកងធំ - វរធំ១២ កងពល៣១០ ក្លាប់មិនបាន ៧

១១.- កុក នាទី ភស្តុភាកងធំ - វរធំ១២ កងពល៣១០ ពលីហើយ ៧

១២.- សាន នាទី ន.បកងធំ - វរធំ១២ កងពល៣១០ នៅវរតូច៣១៧ ៧

| | | | | | | |
|---|---|---|---|---|---|---|
| ១៣.- | ហៀន | នារី យ.ធកងធំ - | វធំ១២ | កងពល៣១០ | នៅវតូច៣១៧ | ៗ |
| ១៤.- | បន | នារី យ.ធកងធំ - | វធំ១២ | កងពល៣១០ | នៅវតូច៣១៧ | ៗ |
| ១៥.- | ថាន | នារី ភស្តុភាកងធំ - | វធំ១២ | កងពល៣១០ | នៅវតូច៣១៧ | ៗ |
| ១៦.- | ថន | នារី ភស្តុភាកងធំ - | វធំ១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ១៧.- | ខឿន | នារី ស.ជកងតូច - | វធំ១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ១៨.- | សុង | នារី ន.បកងតូច - | វធំ១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ១៩.- | អៀង | នារី ន.បកងតូច - | វធំ១២ | កងពល៣១០ | នៅវតូច៣១៧ | ៗ |
| ២០.- | សុង | នារី ន.បកងធំ - | វធំ១២ | កងពល៣១០ | នៅវតូច៣១៧ | ៗ |
| ២១.- | សីន | នារី ន.បវតូច១២២ | -១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ២២.- | ស៊ីម | នារី ន.បវតូច១២៤ | -១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ២៣.- | ហ៊ីម | នារីអនុន.ប - ១២៤ | -១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ២៤.- | លាន | នារី យ.ធវតូច១២៤ | -១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ២៥.- | ដឿន | នារី ភស្តុភា - ១២៤ | -១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ២៦.- | សឿន | នារី ន.បកងធំ - | -១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ២៧.- | ខាន់ | នារី ន.បកងធំ - | -១២ | កងពល៣១០ | ចាប់ហើយ | ៗ |
| ២៨.- | ទៀម | នារី ន.បកងធំ - | -១២ | កងពល៣១០ | នៅវតូច៣១៧ | ៗ |

២៩.- ព្រេន នារី យ.ធកងធំ - វ៉ធំ១២ កង៣ល៣១០ នៅវិតូប៣១៧ ៧

៣០.- ស្រឿន នារី យ.ធវ៉តូច១២២ - ១២ កង៣ល៣១០ ចាប់ហើយ ៧

៣១.- យ៉ង់ នារីយ.ធកងតូច វ៉តូច១២១ កង៣ល៣១០ នៅកងតាតា ៧

៣២.- គី នារី អនុក្រុម វ៉តូច១២១ កង៣ល៣១០ ភ្ជាប់មិនបាន ៧

៣៣.- ទី នារីយ.ធកងតូច វ៉តូច១២៤ កង៣ល៣១០ នៅវិតូប៣១៧ ៧

៣៤.- ទេ្យា នារីស.ជកងតូច វ៉តូច១២៤ កង៣ល៣១០ នៅវិតូប៣១៧ ៧

៣៥.- ជៀប នារីយ.ធកងតូច វ៉តូច១២៤ កង៣ល៣១០ ភ្ជាប់មិនបាន ៧

៚

៚ ៚

**អត្តបទនយ៍ប្រវត្តិសកម្មភាពរបស់ខ្ញុំ**
**ឈ្មោះ ឌៀប.ទឹង ហៅណាត**
**ក្នុងការទាក់ទងគ្នា តាំងពីមុន+បច្ចុប្បន្ន**

- ខ្ញុំឈ្មោះ ឌៀប.ទឹង ហៅ ណាត កើតនៅភូមិតាំងក្រង ឃុំតាំង-ក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ឪពុកឈ្មោះ ជែកវ.ឌៀប ស្លាប់-ម្តាយឈ្មោះ អ៊ុំ.ទឹម នៅរស់ ។ របររកស៊ីធ្វើស្រែ វណ្ណៈភាពជាកសិករកណ្តាលថ្នាក់ក្រោម មានបងប្អូន ៦ នាក់ ប្រុស ៤ នាក់ ស្រី ២ នាក់ ចូលធ្វើបដិវត្តន៍ ២ នាក់ ទាំងរូបខ្ញុំ នៅសហករណ៍ ៤ នាក់ ។

- ខ្ញុំឈ្មោះ ឌៀប.ទឹង.ហៅ ណាត កើតនៅឆ្នាំ ១៩៤៩ សព្វថ្ងៃអាយុ ២៨ ឆ្នាំ ភេទប្រុស ជាតិខ្មែរ នៅលីវ ចំពោះរូបខ្ញុំចាប់តាំងពីដឹងក្តីកាលណាមក គឺរស់នៅជាមួយឪពុកម្តាយរហូតដល់ឆ្នាំ ១៩៦០ ខ្ញុំអាយុ ២១ឆ្នាំ ឪពុកម្តាយខ្ញុំអោយខ្ញុំទៅរៀន នៅសាលាវត្តតាំងក្រសៅ តែក្នុងរយៈពេលដែលខ្ញុំរៀននេះ គឺរដូវវិស្សាខ្ញុំរស់នៅជាមួយលោកវត្តតាំងក្រសៅនេះ តែរដូវប្រាំងខ្ញុំមកនៅជាមួយឪពុកម្តាយវិញ រហូតដល់ខ្ញុំរៀនត្រឹមថ្នាក់ទី៩ ត្រូវនឹងឆ្នាំ ១៩៦៥ ទើបឪពុកម្តាយខ្ញុំ អោយខ្ញុំបួសជាលោកសង្ឃ នៅក្នុងវត្ត

តាំងក្រសោនេះ រហូតមកដល់ឆ្នាំ ១៩៧០ ខ្ញុំក៏ឈប់បួសជាលោកសង្ឃ ហើយនៅជួយរកស៊ីឪពុកម្តាយរបស់ខ្ញុំ រហូតមកទល់ពាក់កណ្តាលឆ្នាំ ១៩៧០ ទើបខ្ញុំចូលធ្វើជាកងឈ្លប យាមកាមតាមភូមិផង និងជួយរកស៊ីធ្វើស្រែជាមួយឪពុកម្តាយខ្ញុំផង រហូតដល់ថ្ងៃ ២៣.៦.៧៣ ទើបខ្ញុំចូលធ្វើបដិវត្តន៍ តែខ្ញុំចូលធ្វើបដិវត្តតំបូងនៅក្នុងមន្ទីរសង្កាត់សំបូរ ស្រុកកំពង់ធំ ខេត្តកំពង់ធំ អ្នកទទួលខុសត្រូវឈ្មោះ សិន នាទី ប្រធានសង្កាត់ បច្ចុប្បន្ន ក្តាប់មិនបាន ខ្ញុំរស់នៅក្នុងមន្ទីរនេះ អស់រយៈពេលមួយខែ ទើបឈ្មោះ សិននេះចាត់តាំងអោយខ្ញុំមកនៅក្នុងអង្គភាពទ័ពស្រុកកំពង់ស្វាយ តំបន់៤៣ អ្នកទទួលខុសត្រូវឈ្មោះ ស៊ូរ នាទីប្រធានយោធាស្រុក បច្ចុប្បន្ន ក្តាប់មិនបាន ខ្ញុំរស់នៅក្នុងអង្គភាពកងទ័ពស្រុកនេះ គឺឈ្មោះ ស៊ូ និងឈ្មោះផ្សេងទៀត ឥតមានអប់រំអោយរូបខ្ញុំក្បត់និងបក្សទេ រហូតដល់ខែ ៩.៧៣ ទើបឈ្មោះ ស៊ូ ចាត់តាំងខ្ញុំអោយមក-នៅក្នុងអង្គភាព វរៈសេនាតូច ៣១៤ ប្រចាំភូមិភាគឧត្តរ អ្នកទទួលខុសត្រូវឈ្មោះ ឯម នាទី លេខាវរៈសេនាតូច បច្ចុប្បន្ន ក្តាប់មិនបាន ខ្ញុំនៅក្នុងអង្គភាពនេះ គឺមិនទាន់មានពីណាម្នាក់ មកដឹកនាំអោយខ្ញុំក្បត់និងបក្ស មានតែកម្មាភិបាល និងមិត្តយើងផ្សេងៗទៀត ទាក់ទងគ្នា វាយខ្មាំងជាបន្តបន្ទាប់-រហូតដល់ខែ ១០.៧៤ ទើបឈ្មោះ ដៃ នាទិ លេខាកងធំ បច្ចុប្បន្នក្តាប់ពុំបាន

ចាត់តាំងខ្ញុំអោយមកនៅក្នុងកងស៊ើបការ ប្រចាំវិរៈសេនាធំ ៥៧ មាន
អ្នកដឹកនាំឈ្មោះ ខាន់ នាទី ប្រធានកងតូច បច្ចុប្បន្ន អង្គការចាប់-។
- ក្នុងរយៈកាលនេះ ខ្ញុំបានទទួលនាទីជា អនុក្រុម តែមិនទាន់ឈ្មោះណាម្នាក់
អប់រំខ្ញុំអោយក្បត់និងបក្សទេ គឺមានតែរួមប្រស្រ័យទាក់ទងគ្នា រាយខ្នាំងជា
ធម្មតា រហូតដល់ខែ ២.៧៥ ទើបឈ្មោះ ខាន់ ចាត់តាំងអោយខ្ញុំមកនៅ
ក្នុងអង្គភាព វិរៈសេនាតូច ៧១៨ ក្នុងវិរៈសេនាធំ ៥៧ ដដែល អ្នកដឹកនាំ
ឈ្មោះ សឺន នាទី លេខាវិរៈ បច្ចុប្បន្ន អង្គការចាប់ ក្នុងរយៈពេលនោះ
ខ្ញុំបានទទួលនាទីជា នយោបាយកងតូច និងភស្តុភាកងធំ អ្នកចាត់តាំងឈ្មោះ សឺន
ខ្ញុំចូលមករស់នៅក្នុងអង្គភាពនេះ មុនដំបូងគ្មានបញ្ហាអ្វីចោទឡើងទេ រហូត
ដល់ខែ ៩.៧៥ ទើបឈ្មោះ សឺន ក៏ចាប់គៀកកិតជាមួយខ្ញុំ ហើយលើសម្ភារៈ
ផ្សេងៗ គឺសឺន ក៏យកមកអូសទាញផ្នែកនយោបាយ សតិអារម្មណ៍មកលើរូបខ្ញុំ ជា
បន្តបន្ទាប់ រហូតខ្ញុំមានសតិអារម្មណ៍ និងគោលជំហរស្រឡាញ់សឺន ទុកចិត្តសឺន
ទាំងស្រុង ។ ក្រោយមកសឺនក៏ក្តាប់បាននូវគោលជំហរ សតិអារម្មណ៍របស់ខ្ញុំ
ឃើញថាស្រឡាញ់គាត់ហើយ សឺនក៏ចាប់ផ្តើមអប់រំរូបខ្ញុំបន្តិចម្តងៗ រហូតដល់
សឺនទុកចិត្តមកលើខ្ញុំ ទាំងស្រុង ទើបសឺនអប់រំ អូសទាញផ្នែកនយោបាយមកលើ
រូបខ្ញុំ ដោយលើកខ្លឹមសារយ៉ាងជ្រៅៗ ធ្វើអោយខ្ញុំមើលឃើញនូវអនាគតរបស់

ខ្ញុំយ៉ាងច្បាស់លាស់ គឺ: អោយខ្ញុំស៊ីចុក ផឹកស្រា ដើរលេងសេរីជាមួយមិត្ត យើងដទៃទៀត និងលើកអំពីបដិវត្តន៍តែងតែង ស៊ីចុកមិនឆ្អែត គ្មានសប្បាយ ហើយលើកទៀតអំពីរបបថ្មី មានមុខមាត់បុណ្យសក្តិ សំបូរសប្បាយហូរហៀរ ដើរលេងបានតាមចិត្ត ។

-ក្រោយពីពន្យល់មិលារដូចខាងលើនេះហើយ ខ្ញុំក៏បញ្ជាក់ប្រាប់ទៅឈ្មោះ សឺនវិញថា: ខ្ញុំសុខចិត្តធ្វើតាមគាត់ទាំងអស់ តែក្នុងរយ:ពេលដែលសឺនអប់រំហើយ សឺនមិនទាន់បញ្ចូលរូបខ្ញុំ អោយទៅជាអង្គការក្បត់អីទេ រហូតមកដល់ខែ ១២.៧៥ អង្គការក៏បាត់តាំងខ្ញុំ និងមិត្តយើងផ្សេងពូទៀតជាច្រើន ទៅទទួលប្រធានម៉ៅសេងទុង នៅឯអង្គរវត្ត អស់រយ:ពេលប្រហែល ១៥ ថ្ងៃ ទើបខ្ញុំត្រឡប់មកអង្គភាពវិញ ហើយខ្ញុំក៏បន្តធ្វើការងារជាធម្មតា រហូតដល់ថ្ងៃ ១.១.៧៦ វរ:សេនាធំ ៥៧ ទាំងមូលត្រូវអង្គការរំសាយ ដូច្នេះ យុទ្ធជន និង កម្មាភិបាលទាំងអស់នៅក្នុងអង្គភាពនេះ ត្រូវបែកគ្នាទៅនៅតាមវរ:សេនាធំ ១១ វរ:សេនាធំ ១២ វរ:សេនាធំ ១៣អស់ តែចំពោះឈ្មោះ សឺន ទៅនៅក្នុងវរ:សេនាធំ ១២ ទទួលនាទីជា លេខាវរ:សេនាតូច ១២២ ឯរូបខ្ញុំមកនៅក្នុងវរ:សេនាតូច ១២១ ក្នុងវរ:សេនាធំ ១២ដែរ តែខ្ញុំទទួលនាទីជា យោធាកងធំ អ្នកដឹកនាំឈ្មោះ វ៉ាន់ - ណូ - ស៊ែ និង

ធាន នារី ជាគណៈវីរៈសេនាតូចនេះ ពេលដែលខ្ញុំមករស់នៅក្នុងអង្គភាពនេះ ដំបូងខ្ញុំធ្វើការងារជាមួយយុទ្ធជន នៅក្នុងអង្គភាពជាធម្មតា រហូតមកដល់ថ្ងៃ ១២.១.៧៦ ទើបឈ្មោះ ស៊ីន នារី លេខាវីរៈសេនាតូច ១២២ - ណន និង វ៉ាន់ ហៅរូបខ្ញុំ - ផាន - សាង - កុក - និង ឈឿន មកបញ្ចូលជាសមាជិក បក្សពលករវៀតណាម នៅវេលាម៉ោង ៧ ល្ងាច ដល់ម៉ោង ៨ យប់ទើបបិទកម្មវិធី ។ ទីកន្លែងបញ្ចូល នៅផ្ទះណន ឯភូមិអន្លង់ក្តាន ។

- ក្នុងពេលបើកកម្មវិធីបញ្ចូលខ្ញុំនេះ ឈ្មោះ ណន - វ៉ាន់ -និងស៊ីនបានឡើងធ្វើការណែនាំដល់សមាជិកថ្មីទាំងអស់ ដែលមានខ្លឹមសារសំខាន់ៗ ដូចតទៅគឺ:
  - ណែនាំអោយសមាជិកទាំងអស់ មើលឃើញនូវអនាគតរបស់បក្សពលករ -
  - ណែនាំអោយធ្វើសកម្មភាព ប្រឆាំងនិងបដិវត្តន៍ជាដាច់ខាត ទោះបីមានឧបសគ្គយ៉ាងណាក៏ដោយ តែស្មោះត្រង់ជាមួយ បក្សពលករ ។
  - ណែនាំអោយប្រមូលកម្លាំង អោយបានច្រើន ដើម្បីជួយធ្វើសកម្មភាព - ប្រឆាំងនិងបដិវត្តន៍ ។
  - ណែនាំអោយរក្សាការសម្ងាត់ជាដាច់ខាត អំពី បក្សពលករ ។
- បន្ទាប់ពីធ្វើការណែនាំហើយ វ៉ាន់ក៏ឡើងឧទ្ទេសនាមដល់សមាជិកថ្មីទាំងអស់ អោយធ្វើការទាក់ទងជាមួយ ស៊ែ - ណូ និង ធាន ក្នុងការធ្វើសកម្មភាពប្រឆាំង

និងបដិវត្តន៍ ។ ឯចំពោះ សឺនក៏ឡើងឧទ្ទេសនាម អោយសមាជិកថ្មីទាំង ៥ នាក់ ហើយនិងរូបខ្ញុំធ្វើការទាក់ទងជាមួយស្រឿន នៅវិរៈសេនាតូច ១២២ ព្រោះមិត្តស្រឿននេះជា បក្សពលករដែរ ។

- បន្ទាប់ពីប្រកាស់ឧទ្ទេសនាម និងរៀបចំរួចស្រេចបាច់ហើយ ណនក៏ឡើងប្រកាសបិទកម្មវិធី នៅវេលាម៉ោង ៨ យប់នោះទៅ ឯសមាជិកទាំងអស់ ក៏បែកគ្នាទៅកន្លែងតាមរៀងៗខ្លួនវិញ ។

- ក្រោយពីចូលជាសមាជិក បក្សពលករហើយ ខ្ញុំក៏ចាប់ផ្ដើមធ្វើសកម្មភាពប្រឆាំងនិងបដិវត្តន៍ គឺ បំផុសយុវជនអោយខ្ជិលធ្វើការងារ ដើរហើរសេរី បំផុសយុវជនអោយលើកភ្លឺធំពុះពក តូចពុះពក បួសផែនការណ៍របស់អង្គការ-កំណត់ បញ្ជាអោយយុវជន និង កម្មាភិបាលខាងក្រោមធ្វើការងារគ្មានពេលម៉ោងសម្រាក និងខ្ញុំផ្ទាល់បានបំផ្លាញកាំភ្លើងអាកាអស់មួយដើម យុទ្ធវិធី-ទុកចោលក្នុងទីព្រៃភូមិកប់ស្រូវ សេរីប្រើអាផ្លាផាក់បងប្អូន ធ្វើអោយបងប្អូនខ្លាចជាបន្តបន្ទាប់ រហូតដល់ខែ ២.៧៦ ទើបវ៉ាន់ចាត់តាំងអោយខ្ញុំមករៀនបច្ចេកទេសកាំភ្លើងធំ នៅសាលាកងពល៣១០ តែក្នុងរយៈនេះខ្ញុំផ្អាកសកម្មភាព ហើយខិតខំរៀនជាបន្តបន្ទាប់ រហូតមកដល់ខែ ៥.៧៦ ខ្ញុំក៏ត្រឡប់ទៅអង្គភាពវិញ បន្ទាប់ពីមកដល់អង្គភាពបានរយៈ ៣ ថ្ងៃ វ៉ាន់ក៏ចាត់

តាំងអោយរូបខ្ញុំ និង យុទ្ធជន ១០ នាក់ទៀតមកធ្វើដីដាក់ស្រែ នៅឯភូមិ ឃ្មុញ ក្រោយពីទៅដល់ភូមិឃ្មុញហើយ ខ្ញុំក៏បន្តធ្វើសកម្មភាពទៀត គឺៈ ធ្វើដីមិនអោយគ្រប់តាមកំណត់របស់អង្គការ និងបញ្ជាអោយយុទ្ធជនមិនអោយ យកអាចម៍គោទៅដាក់ក្នុងកំប្លោក និងសារាយទេ គឺអោយយកកំប្លោក- និងសារាយធ្វើជាដី តែអាចម៍គោអោយយកទៅលាយជាមួយដី គឺអាចម៍ គោមួយភាគ ដីបួនទៅប្រាំភាគ ជាបន្តបន្ទាប់ និងបំផុសយុទ្ធជន អោយដើរ លួចដំឡូង ផ្លែចេក និងចំនាស់គ្នាជាបន្តបន្ទាប់ រហូតដល់ខែ ៥.៧៦ វ៉ាន់ ក៏ហៅខ្ញុំមកកន្លែងគាត់ នៅភូមិខ្មែរលើ មកប្រជុំរៀបចំផែនការណ៍ប្រមូល- គ្រាប់ទំនេរដែលនៅសេសសល់ យកទៅបំផ្លាញចោល និងបន្តការកសាង កម្លាំងថែមទៀត ហើយនិងពង្រឹងគោលជំហរមួយចំនួនទៀត ។

- បញ្ជាក់ : ក្នុងពេលប្រជុំនេះមានឈ្មោះ សែ - ញូ - ធាន - ងឹម ទៀន - តាក់ - ថន ជាអ្នកចូលរួមប្រជុំដែរ ។

- បន្ទាប់ពីរៀបចំផែនការណ៍ហើយ ខ្ញុំក៏ត្រឡប់មកកន្លែងធ្វើដីនៅឯ ឃ្មុញវិញ ហើយខ្ញុំអនុវត្តន៏តាមផែនការណ៍របស់វ៉ាន់ ក្នុងរយៈខែ ៥.៧៦នោះ គឺៈ ចាត់តាំងអោយយុទ្ធជនដើរប្រមូលគ្រប់ អឹម៣០ - អាកា - អ៊ាកែងនិង គ្រាប់ផ្សេងៗទៀតជាច្រើន យកមកទុកចោលជាបន្តបន្ទាប់ តែក្នុងរយៈ

ខែ៦ ៥នេះ ខ្ញុំកសាងកម្លាំងបាន ២ នាក់គឺ : យ៉ង់ និង គី បញ្ជាក់ : ចំពោះឈ្មោះ ២ រូបនេះក្រោយពីកសាងបានហើយ ខ្ញុំរាយការណ៍អោយទៅឈ្មោះ រ៉ាន់ - ស៊ែ - ណូវ ជាអ្នកបញ្ជូល ។ ឆ្លងកាត់ចូលមកដល់ខែ ៦.៧៦ ឈ្មោះ រ៉ាន់បានអោយកម្លាំងធ្វើជីរបស់ខ្ញុំ ១០ នាក់ដែលនៅឃ្មុញនេះត្រឡប់មកនៅភូមិខ្មែរលើវិញ ក្រោយពីខ្ញុំមកនៅភូមិខ្មែរលើបានតែ ២ ទៅ ៤ ថ្ងៃប៉ុណ្ណោះ ឈ្មោះ រ៉ាន់ - ស៊ែ - ណូវ ក៏ហៅខ្ញុំ និង ងឹម - តាក់ - ថន - ស៊ុង - អៀង - នឿន - ស៊ុង - ថាន - ចន ហៀន - សាន - កុក - ឈឿន - ទៀន - ផាន - សាង - និង - ផាន ។ល។ មកប្រជុំអោយរៀបចំគ្រាប់សេរ៉ និងកាំភ្លើងតូចធំ ហើយ និងកម្លាំងមនុស្សអោយមានរបៀបរៀបរយ ទុកវាយបដិវត្តន៍នៅថ្ងៃមុខ និងអោយអនុវត្តន៍ផែនការណ៍ចាស់ជាបណ្តើរពុសិន ទំរាំនិងដល់ថ្ងៃវាយបដិវត្ត ។

- បន្ទាប់ពីប្រជុំរួចហើយ ខ្ញុំមិនទាន់បានអនុវត្តន៍នៅផែនការណ៍នេះទេ អស់រយៈ ៨ ថ្ងៃទើបរ៉ាន់ ចាត់តាំងអោយរូបខ្ញុំ និង ឈ្មោះ អៀង - សាង ទៅពិនិត្យប្រវត្តិរូបយុទ្ធជនក្នុងអង្គភាព នៅខាងខ្នួរ ចាប់តាំងពីពាក់កណ្តាលខែ ៦ រហូតដល់ខែ ៩.៧៦ ចំនួន ៣ ដង ។

បញ្ជាក់ : ក្នុងចន្លោះពីខែ ៦ រហូតដល់ខែ ៩នេះ ខ្ញុំផ្អាកសកម្មភាព

លុះពេលខ្ញុំត្រឡប់មកពីពិនិត្យប្រវត្តិរូបវិញ នៅចុងខែ ៩.៧៦ដដែល វ៉ាន់ ក៏ចាត់តាំងអោយរូបខ្ញុំមកនៅក្នុងអង្គភាព វិរៈសេនាតូច ១២៥ ក្នុងវិរៈសេនាធំ ១២ ដដែល តែមុននឹងចេញមក ណន និង វ៉ាន់ បានណែនាំខ្ញុំអោយមកធ្វើសកម្មភាពទាក់ទងជាមួយឈ្មោះ ស៊ុម - ហ៊ុម និង សាន នៅក្នុងអង្គភាព វិរៈសេនាតូច ១២៥ នោះ ។ ពេលដែលខ្ញុំមកនៅក្នុងអង្គភាពនេះភ្លាម ស៊ុម ប្រាប់ខ្ញុំអោយនៅក្នុងមន្ទីរជាមួយនឹងសាររបស់គាត់សិន ហើយគាត់ក៏ចេញមកទៀននៅសាររបស់អង្គការ អស់រយៈមួយខែខាង ទើបស៊ុម - ត្រឡប់មកវិញ ហើយក៏ចាត់តាំងអោយខ្ញុំទទួលនាទីជា យោធាកងធទី១ នៅក្នុងវិរៈសេនាតូចនេះ ពេលដែលខ្ញុំចូលមករស់នៅក្នុងអង្គភាពនេះ មុនដំបូងខ្ញុំមិនទាន់ហ៊ានធ្វើសកម្មភាពអ្វីខ្លាំងក្លាដែរ គ្រាន់តែខ្ញុំធ្វើសកម្មភាព បំផុសយុទ្ធជន អោយខ្ជិលធ្វើការងារ លួចស៊ីចុកបុគ្គល់ រហូតដល់ខែ ១២.៧៦ ខ្ញុំធ្វើសកម្មភាព បង្ហូរទឹកចេញពីស្រែ ធ្វើអោយស្រូវស្លកអស់ចំនួន ៥ ហិតា និងនិយាយប្រើអាថ្វាជេរស្តីដាក់យុទ្ធជន ធ្វើអោយយុទ្ធជនខ្លាចញញើត រហូតចង់លែងហ៊ានមើលមុខខ្ញុំ ជាបន្តបន្ទាប់ លុះចូលមកដល់ខែ ១.៧៧ ស៊ុម និង ហ៊ុម បានហៅខ្ញុំ និង ជឿន - សឿន - ខាន់ - រៀម និង ព្រេន មកប្រជុំប្រកាស់អោយឈ្មោះខាងលើ និង រូបខ្ញុំស្គាល់គ្នា ក្នុងការធ្វើសកម្មភាពប្រឆាំងបក្ស

តែក្នុងពេលប្រជុំនេះ ស៊ុម និង ហ៊ីមបានណែនាំអោយឈ្មោះខាងលើ និងរូបខ្ញុំ បំផ្លាញកម្លាំងបដិវត្តន៍ និងបំផ្លាញផលបដិវត្តន៍ ហើយនិងអោយប្រមូល-កម្លាំងអោយបានច្រើននៅក្នុងរយៈនេះ ដើម្បីធ្វើសកម្មភាពប្រឆាំងនិងបក្ស ទីកន្លែងនៅភូមិសំរោងទង ។ ក្រោយពីប្រជុំហើយ ចំនួន ៣ ថ្ងៃ ស៊ុម ក៏ចាត់តាំងកងធំរបស់ខ្ញុំ អោយមកនៅទួលសង្កែវិញ ពេលមកដល់ទួលសង្កែភ្លាម កងធំរបស់ខ្ញុំមានមុខព្រួញខាងដកសំណាប ស្ទូងស្រូវបណ្តេញទឹក តែក្នុងពេលដកសំណាបនេះ ខ្ញុំបានបំផ្លាញសំណាបអស់ជាបន្តបន្ទាប់-ដូចជា បញ្ជាអោយបងប្អូនដកសំណាបអោយរហ័ស ធ្វើអោយដាច់ច្រើន និងដកសំណាបមិនអោយអស់ពីក្នុងថ្នាល និងទុកសំណាបចោលអោយរលួយ រហូតដល់ថ្ងៃ ២០.១.៧៧ ដដែល ស៊ុម បានអោយខ្ញុំទៅទទួលផែនការណ៍ពីគាត់ គឺៈ ណែនាំពង្រឹងគោលដៅមួយចំនួន និងលើកផែនការណ៍ចាស់ទៀត ។បន្ទាប់ពីទទួលផែនការណ៍ហើយ ខ្ញុំក៏យកអនុវត្តន៍ កសាងកម្លាំង បាន ១ នាក់-ឈ្មោះ នី ដោយខ្ញុំរាយការណ៍អោយ ស៊ុំ និង ហ៊ីម បញ្ចូលរួចហើយ តែក្នុងខែនេះ ខ្ញុំធ្វើសកម្មភាពដដែល ផ្នែកខាងសំណាប លុះចូលមកដល់ខែ ២.៧៧ កងធំរបស់ខ្ញុំមានមុខព្រួញខាងរៀបដីអោយគេស្ទូងបណ្តេញទឹក ហើយខ្ញុំក៏ធ្វើសកម្មភាពបំផ្លាញកម្លាំងបដិវត្តន៍ គឺៈ បញ្ជាអោយយុវជននៅក្នុង-

អង្គភាព អោយធ្វើការងារគ្មានមានពេលម៉ោងសម្រាក យុទ្ធជនឈឺ អោយ ទៅធ្វើការងារដែរ រហូតយុទ្ធជនឈឺជាធ្ងន់ ស្គម .ស្លាំងអស់មួយចំនួន ហើយ ជេរស្តី គំរាមកំហែងដាក់យុទ្ធជនជាខ្លាំងពុ បន្ទាប់មកខ្ញុំកសាងកម្លាំងបាន ២ នាក់ទៀតគឺៈ ជៀប និង ទេ្វា តែខ្ញុំបានរាយការណ៍អោយទៅ ស៊ុម ហើយ តែមិនដឹងស៊ុមបញ្ចូលឬនៅទេ រហូតមកដល់ខែ ៥.៧៧ អង្គការ ក៏បើកសភារបស់យុទ្ធជន ហើយយុទ្ធជនគាត់ចោទខ្ញុំ រហូតទំលាក់ខ្ញុំពីនាទីយ.ធ កងធំ មកជា យុទ្ធជនធម្មតាវិញ ។ ក្រោយពីប្រជុំរួច អង្គការក៏ចាត់ តាំងអោយខ្ញុំមកនៅក្នុងអង្គភាព ៣១៧ កងពល៣១០ ខ្ញុំទទួលនាទីជាយុទ្ធជន ងខែប្រកប្រពួកខ្ញុំ ដែលនៅក្នុងអង្គភាព វរៈសេនាតូច ៣១៧ នេះ ក៏មាន ដែរ តែខ្ញុំមិនហ៊ានទាក់ទងគ្នា ដើម្បីរៀបចំផែនការណ៍ប្រឆាំងនិងបក្ស- ទៀតទេ មូលហេតុអង្គការកំពង់តែតាមដាន នូវសកម្មភាពនេះ តែ ចំពោះរូបខ្ញុំ មិនហ៊ានធ្វើសកម្មភាពខ្លាំងក្លាទេ គ្រាន់តែធ្វើសកម្មភាព ដូចជា បេះបោះផលដំណាំ ដែលអង្គការហាមឃាត់ ពុតត្បុតខ្ជិលធ្វើការងារ ធ្វើ ការងារមិនទទួលខុសត្រូវ ខ្ជះខ្ជាយ ស្ពឹកស្រពន្ធ និងនិយាយទំនាស់ជាមួយមិត្ត យើងនៅក្នុងអង្គភាព ជាបន្តបន្ទាប់ រហូតដល់ថ្ងៃ ២៩.៨.៧៧ អង្គការ ក៏ចាប់ខ្លួនខ្ញុំមកទល់សព្វថ្ងៃនេះ ។

សារុប សកម្មភាព របស់ខ្ញុំ ឈ្មោះ ឌៀប.ទីង

ហៅ. ណន -

-------------------

- នៅខែ ៥.៧៦ - បានបំផុសលើកភ្លឺធំពេក តូចពេកខុសផែនមារណ៏ របស់ អង្គការ បញ្ជាអោយយុទ្ធជនធ្វើការងារគ្មានពេលម៉ោងសំរាក - បំផ្លាញកាំភ្លើង អាការមួយដើម ដោយយកទៅបាញ់សត្វហើយទុកចោល -

- ចាប់តាំងពីខែ ៣ រហូតដល់ខែ១៥ ឆ្នាំ៧៥ - ណាតអស់បញ្ជាកសកម្មភាពៗ

- នៅចុងខែ ៥.៧៦ - ណាត់ បំផ្លាញដី ដូចជា បញ្ជាអោយយុទ្ធជន - យកកំប្លុក និងសារាយធ្វើជាដី ឯអាចម៍គោមួយភាគទៅលាយជាមួយដី - ៥ ទៅ៥ ភាគ ធ្វើអោយខាចម៏គោឥស្សូមួយចំនួន ដែលណាតអស់កំណត់ ៗ

- នៅខែ ៦.៧៦ - ណាតបញ្ជាអោយយុទ្ធជន ប្រមូលគ្រាប់កាំភ្លើង - អាកា ម៉ែអ៊ិ១៥ - អឹម៣០ និងគ្រប់កាំភ្លើងផ្សេងៗទៀត យកទៅដុតចោល - ជាបន្តបន្ទាប់ ដែលណាត់អស់កំណត់ ៗ និងណាត់បានប្រជុំជាបក្សពួកខ្ញា ទៀបចំអាវុធ និងមនុស្ស បំរុងវាយបក្ស ៗ

- ចាប់តាំងពីចុងខែ ៧ រហូតមកដល់ ដើមខែ ៨ ណាត់អស់បញ្ជាកសកម្មភាព -

- នៅចុងខែ ៨.៧៦ - ណាត់ត្រូវវិរាន់ ចាត់តាំង អោយចេញពី អង្គភាព

១២១_ មកនៅអង្គភាពវ.ត ១២៤ វ.ធំ ១២ជាមួយ តែរ៉ាន់អោយណាត_
ធ្វើការទាន់ទងជាមួយឈ្មោះ ស៊ុម _ហ៊ុម_ សាន_ ពេលណាតមកដល់វ.ត ១២៤
ណាតបានធ្វើការទាក់ទង និងឈ្មោះ ស៊ីម_ហ៊ីម_ តែលកម្មភាពរហូត ដល់_
ខែ ១១.៧៦_ ណត់អត់បញ្ហាក់ ។

_ នៅខែ១២.៧៦ _ ជារដូវស្រូវជិតទុំ ណត់បានបង្ហូរទឹកចេញពីក្នុងស្រែ_
ធ្វើអោយស្រូវស្អក ៥ ហិកតា និងប្រើអង្គាដាក់ យុទ្ធជន រហូតយុទ្ធជន ញញើត
លែងហ៊ានមើលមុខ ។

_ នៅខែ ១.៧៧_ ណាតបានត្រូវស្គាល់ ឈ្មោះ ជឿន_ សឿន_ខាន់_
វៀម_ ព្រេន_ ដោយឈ្មោះ ស៊ុម_ហ៊ុម_អោយចូលរួមប្រជុំដាក់ផែនការណ៍_
ក្បត់ _ ហើយណាតបានបំផ្លាញសំណាប ដូចជាបញ្ជាអោយ យុទ្ធជនដកអោយ
រហ័ស ធ្វើអោយដាច់ សល់សំណាប់នៅក្នុងខ្ទាល រលួយអស់ ជាបន្តបន្ទាប់ តែ_
ណត់អត់បញ្ហាក់ ។ ក្នុងខែ ១៨ដែល_ ណាតបានកសាងកម្លាំងមួយនាក់_
_ឈ្មោះ នី ដោយណាត រាយការណ៍ អោយទៅ ឈ្មោះ ស៊ុម_ហ៊ុម_បញ្ជូល ។
ពីខែ ២ ដល់ ចុងខែ ៤ ឆ្នាំ៧៧_ ណត់បានបំផ្លាញ កម្លាំងបដិវត្តន៍ណាត_
បញ្ជាអោយយុទ្ធជនទៅធ្វើការងារស្ពានពេលសំរាក យុទ្ធជនឈឺក៏អោយទៅ
ធ្វើការ រហូតយុទ្ធជនស្គមស្គាំ ជាបន្តបន្ទាប់ ហើយកសាងកម្លាំងបាន ២ នាក់_

គឺ ឈ្មោះ ផៀប-ទៀា ដែណាត រាយការណ៍អោយទៅឈ្មោះ ស៊ុម-ញ៉ុម-

ហើយមិនដឹង ស៊ុម-ញ៉ុម-គេបញ្ជូលហើយឬនៅទេ ឈ្មោះទាំង ២រូបនេះ-ៗ

-នៅខែ១ ៥. ៧៧-ណាតត្រូវយុទ្ធជន កាត់ទោស ហើយទម្លាក់ពី នាទីជា-

អងធំ មកជា យុទ្ធជន ហើយត្រូវអង្គការដកអោយទៅនៅ អង្គភាព-

វ.ត ៣១៧ -កងពល ៣១០ - ពេលដែលណាតមកដល់អង្គភាពនេះ ណាត-

ត្រូវជួបបក្សពួកខាងមួយចំនួនដែរ ហើយលើការទាក់ទងណាតអស់បញ្ហាក់ ៗ

ដែណាត នៅតែ បន្តធ្វើសកម្មភាព គឺលួចផលដំណាំ ពុតត្បុតខ្ជិលធ្វើការងារ-

ធ្វើការងារស្ពឹកស្រពន់ និយាយ ទំនាស់ ពីមិត្តមួយទៅមិត្តមួយ នៅក្នុងអង្គភាព-

ជាបន្តបន្ទាប់ ៗ រហូតមកដល់ នៅថ្ងៃទី ២៩.៨.៧៧-អង្គការក៏

ចាប់ខ្លួនណាត មកលហូតដល់ សព្វថ្ងៃនេះ ៗ: -

៚

៚ ៚

ធ្វើនៅថ្ងៃទី ១០.៩.៧៧-

អ្នកសារភាព ឈ្មោះ : ឌៀប- ណាត-

........